នាងបានពន្យល់ដល់អ្នកជិតខាងទាំងនោះ ពីរបៀបដែល ម្ដាយនាង និងនាងបានរៀន ដែលថាមិនមែនសត្វល្អិតទាំង អស់សុទ្ធតែសត្វចង្រៃនោះទេ ។ មានសត្វល្អិតខ្លះជាសត្វមាន ប្រយោជន៍ ហើយកសិករគួរតែព្យាយាមកុំសម្លាប់ពួកវាដោយ ការបាញ់ថ្នាំពុល ។ ធីតាបានបង្ហាញពួកគេនូវប្រភេទសត្វល្អិតចង្រៃដែល បានស៊ីបំផ្លាញដំណាំរបស់ពួកគេ ។





គ្រប់គ្នាបានមើលឃើញពួកស្រឹងបៃតងយ៉ាងច្បាស់ដែល នាងបានចាប់យកមក ហើយបានហុចដបតូចដែលមាន ស្រឹងនោះត១គ្នាជុំវិញហ្វូងមនុស្សទាំងនោះដើម្បីមើល ។

ពួកគេ ( អ្នកជិតខាង) បានរៀនពីរបៀបកំចាត់ពួកស្រឹងបៃ តង ដោយមិនសម្លាប់សត្វល្អិតមានប្រយោជន៍ ។ ចិន្តាបាន និយាយប្រាប់ពួកគេថា វិធីថែទាំដំណាំនេះហៅថា "វិធាន ការចម្រុះគ្រប់គ្រងកត្តាចង្រៃ" ឬអាយភីអឹម (IPM)* ។

*សម្រាប់ព័ត៌មានបន្ថែមអំពី អាយភីអឹម (IPM) សូមមើលនៅទំព័រ ៤៧





"ដូច្នេះ សារ៉េត អ្នកមិនត្រូវបារម្ភណ៏ទេ។ យើងអនុវត្តវិធីសាស្ត្រ អាយភីអឹម (IPM) នៅក្នុងចំការរបស់យើង។ ពួកស្រឹងបៃតងតិចតួចនឹងមិនមានការស៊ីបំផ្លាញខ្លាំងទេ"-យ៉ូរ៉ានី និយាយដោយធានា។

"តើឥឡូវនេះមានសត្វល្អិតមានប្រយោជន៏នៅក្នុងចំការយើងដែរឬទេ?"

"ចាំ! សារ៉េត។ ប៉ុន្តែពួកវាខ្លះមានទំហំតូចៗ អ្នកប្រហែលមិនអាចមើលពួកវាឃើញទេ។ "តើឪពុកម្តាយយើងបានរៀន អាយភីអឹម ដូចម្តេចទៅ?"-សារ៉េតបានសួរ។

"តើអ្នកមិនចាំទេឬ? អ្នកនៅតូចណាស់ នៅពេលដែលយើងត្រូវបានអញ្ជើញទៅផ្ទះធីតានាយប់នោះ"។

# នេះជារឿងរ៉ាវដែលធីតា  និងមិត្តបាននិយាយប្រាប់អ្នកជិតខាងរបស់ពួកគេ។

## ពួកស្រឹងចង្រៃ

ស្រឹងបៃតងជញ្ជក់យករុក្ខរសពីដំណាំ ។ មានសត្វល្អិតជាច្រើនប្រភេទទៀតដែលអាចស៊ីបំផ្លាញដំណាំ ។



ដំណាក់កាលនៃវដ្តជីវិតស្រឹងបៃតង *(Nezara viridula)*

សត្វល្អិតដទៃដែលជញ្ជក់យករុក្ខរសពីដំណាំ មានដូចជាស្រឹងសណ្តែកពណិត្នោត និងពួកចៃ ។

វាក៏មានពួកដង្កូវជាច្រើនប្រភេទទៀតដែរ ដែលញាស់ចេញពីពងរបស់មេអំបៅ ។ ពួកដង្កូវទាំងនោះស៊ីស្លឹក ចោះចូលទៅក្នុងផ្លែ ហើយស៊ីគ្រាប់ ។



ស្រឹងសណ្តែកពណិត្នោត
*(Riptortus linearis)*



ចៃ



ដង្កូវ



មេអំបៅ

## ពួកស្រឹងមានប្រយោជន៍

មានសត្វល្អិតជាច្រើន និងពីងពាងដែលស៊ីសត្វល្អិតដទៃទៀត ។ ពួកវាខ្លះចាប់សត្វល្អិតស៊ីតែម្តង ( សត្វរំពារ ឬប្រេដាទ័រ) ។ ពួកខ្លះទៀតពងដាក់លើ ឬចូលទៅក្នុងខ្លួនសត្វល្អិតផ្សេងទៀត ( ប៉ារ៉ាស៊ិត) ។ ពួកវាទាំងអស់នេះហៅថាសត្វល្អិតមានប្រយោជន៍ ឬ " ស្រឹងមានប្រយោជន៍" ពីព្រោះជាធម្មតាពួកវាមិនស៊ីបំផ្លាញដំណាំនោះទេ ។

មានពួករុយដែលពងដាក់នៅលើខ្លួនស្រឹងបៃតង ជាលទ្ធផលដង្កូវរបស់រុយចោះចូលទៅក្នុងខ្លួនស្រឹងបៃតង និងវិវឌ្ឍន៍នៅក្នុងសត្វនោះ ។

វាក៏មានពួកឪម៉ាល់តូចៗផងដែរ ដែលពងដាក់ចូលទៅក្នុងពងស្រឹងបៃតង ជាលទ្ធផលកូនឪម៉ាល់តូចៗញាស់ចេញមកពីក្នុងពងស្រឹងបៃតងជំនួសកូនស្រឹងបៃតង ។

មានពួកស្រឹងមានប្រយោជន៍ផ្សេងទៀតដែលមិនរើសអើងចំណីទេ វាអាចចាប់សត្វល្អិតចង្រៃបានជាច្រើនប្រភេទ ( សំខាន់គឺស្រឹងបៃតង) ជាចំណី ។ ពួកវាទាំងនោះមានដូចជា ពីងពាង ឪម៉ាល់ កណ្តូបបុកស្រូវ ស្រមោច អណ្តើកមាស និងស្រឹងខែល ។



រុយប៉ារ៉ាស៊ិត
*(Trichopoda pennipes)*






ឪម៉ាល់ប៉ារ៉ាស៊ិត
*(Trissolchus basalis)*



អណ្តើកមាស



ពីងពាង



ស្រមោច



ស្រឹងខែល



កណ្តូបបុកស្រូវ



ឪម៉ាល់ប្រេដាទ័រ



**ឥឡូវនេះ   ជាតួនាទីរបស់អ្នក។**

ប្រាប់អ្នកជិតខាងរបស់អ្នកអំពី អាយភីអឹម **(IPM)** ដូច្នេះយើងអាចជំរុញអ្នកភូមិសំឡូតទាំងអស់អោយរក្សាទុកសត្វល្អិតមានប្រយោជន៏ដើម្បីប្រយុទ្ធប្រឆាំងនឹងស្រឹងបៃតងដ៏កំណាចទាំងនោះ ។



## វិធានការចម្រុះគ្រប់គ្រងកត្តាចង្រៃ (អាយភីអឹម - IPM)

វិធានការចម្រុះគ្រប់គ្រងកត្តាចង្រៃប្រើប្រាស់វិធានការជាច្រើនរួមបញ្ចូលគ្នា ដើម្បីកំចាត់ពួកស្រឹងចង្រៃ ជាលទ្ធផលកសិករអាចកាត់បន្ថយការប្រើប្រាស់ថ្នាំពុលកសិកម្ម ។ វិធានការកំចាត់ខ្លះសម្រាប់ដំណាំសណ្តែកសៀងរួមមាន:

- ធ្វើអោយប្រាកដថា ដំណាំមានសុខភាពល្អតាមដែលអាចធ្វើទៅបាន
- ធ្វើការដាំដុះអោយបានពីដើមរដូវ ដើម្បីជៀសវាងប្រជាករសត្វល្អិតខ្ពស់ដែលជារឿយៗ ធ្លាប់កើតមានចំពោះការដាំដុះយឺតពេល
- ធ្វើការត្រួតពិនិត្យតាមដានកម្រិតកត្តាចង្រៃ ដើម្បីអោយដឹងថា តើទំហំការខូចខាតប៉ុណ្ណាដែលពួកវាបង្កឡើង
- ថែរក្សាការពារពួកស្រឹងមានប្រយោជន៍ដើម្បីជួយក្នុងការកំចាត់ស្រឹងចង្រៃ
- ប្រើប្រាស់ថ្នាំពុលកសិកម្មនៅពេលណាកំពុងមានការបំផ្លាញច្រើន និងផ្លាស់ប្តូរប្រភេទថ្នាំពុលដើម្បីកាត់បន្ថយហានិយភ័យនៃស្រឹងចង្រៃ ដែលអាចក្លាយជាធន់ទ្រាំទៅនឹងថ្នាំគីមីជាក់លាក់ណាមួយ
- ធ្វើការកំចាត់ស្មៅចង្រៃដែលជាជម្រក និងអាចទាក់ទាញស្រឹងចង្រៃអោយមកស៊ីដំណាំ
- ជៀសវាងដំណាំឆ្លាស់ក្នុងកម្មវិធីដំណាំបង្វិលដែលទាក់ទាញពួកស្រឹងចង្រៃ
- ដាំដំណាំអន្ទាក់ (ដំណាំដែលស្រឹងចង្រៃចូលចិត្តស៊ី) ដើម្បីទាក់ទាញស្រឹងចង្រៃអោយឃ្លាតឆ្ងាយពីដំណាំសណ្តែកសៀង
- ពិភាក្សាជាមួយអ្នកជិតខាង និងកសិករផ្សេងទៀតនៅក្នុងតំបន់ដើម្បីអោយពួកគេប្រើវិធានការកំចាត់ដូចគ្នានៅពេលតែមួយ ដើម្បីកំចាត់ពួកស្រឹងចង្រៃជាទ្រង់ទ្រាយធំ
- ធ្វើការជ្រើសរើសពូជដំណាំណាដែលមានលក្ខណៈធន់ទ្រាំល្អទៅនឹងសត្វល្អិត និងជម្ងឺ ។

## សាលារៀនស្រែកសិករ

សាលារៀនស្រែកសិករគឺជា "សាលារៀនគ្មានជញ្ជាំង" ដែលមានកសិករចូលរួមរហូតដល់៣០នាក់ ដែលត្រូវជួបជុំគ្នាមួយសប្តាហ៍ម្តង សម្រាប់ពេញមួយរដូវកាលដាំដុះដំណាំ ។ សាលារៀននេះត្រូវបានបង្កើតឡើង ដើម្បីជួយកសិករអោយរៀនអំពី អាយភីអឹម (IPM) ដូច្នេះពួកគេអាចកាត់បន្ថយការប្រើប្រាស់ថ្នាំពុលកសិកម្ម និងធ្វើអោយប្រសើរឡើងនូវនិរន្តភាពនៃទិន្នផលដំណាំរបស់ពួកគេ ។

អ្នកអាចរៀនអំពី "អាយភីអឹម (IPM)" និងសាលារៀនស្រែកសិករបន្ថែមទៀតពីនាយកដ្ឋានក្សេត្រសាស្រ្ត និងកែលំអរដីកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៃព្រះរាជាណាចក្រកម្ពុជា (www.maff.gov.kh/eng/depts/daald.html) ។



## សេចក្តីថ្លែងអំណរគុណ

សៀវភៅនេះរំឭកដល់ប្រជាជននៅស្រុកសំឡូតប៉ៃកពាយ័ព្យនៃប្រទេសកម្ពុជាដែលបានអបអរសាទរសម្រេចយកគំនិតនៃវិធានការចម្រុះគ្រប់គ្រងកត្តាចង្រៃ (អាយភីអឹម- IPM) ។

យើងសូមថ្លែងអំណរគុណចំពោះការិយាល័យថ្នាក់ស្រុក និងខេត្តនៃនាយកដ្ឋានអប់រំរបស់ប្រទេសកម្ពុជា គ្រូបង្រៀន សិស្សានុសិស្ស និងនាយកសាលាអភិវឌ្ឍន៍សហស្សវត្ស MJP ក្នុងស្រុកសំឡូត ។ លោកប៉ុល ចាន់ធី លោកនិន ចរិយា និងលោកពិន តារា សម្រាប់ការបកប្រែអត្ថបទជាខេមរៈភាសា និង ACIAR ដែលបានផ្តល់ថវិកាសម្រាប់ការស្រាវជ្រាវ និងបោះពុម្ពសៀវភៅ ។